**សុន្ទរកថា**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា**

**ក្នុងវេទិកាសេដ្ឋកិច្ចពិភពលោកស្តីពីអាស៊ានលើកទី ២៧**

**ក្រោមប្រធានបទ**

**«អាស៊ាន ៤.០ ÷ សហគ្រិនភាព និង បដិវត្តន៍ឧស្សាហកម្មលើកទី ៤»**

**ទីក្រុងហាណូយ សាធារណរដ្ឋសង្គមនិយមវៀតណាម ថ្ងៃទី ១១-១៣ ខែ កញ្ញា ឆ្នាំ ២០១៨**

ឃឃឃ✿ឃឃឃ

- ***ឯកឧត្តម ង្វៀន ស្វួនហ៊្វុក នាយករដ្ឋមន្ត្រីនៃសាធារណរដ្ឋសង្គមនិយមវៀតណាម,***
- ***ឯកឧត្តម, លោកជំទាវ ប្រមុខរដ្ឋ ប្រមុខរដ្ឋាភិបាល,***
- ***ឯកឧត្តម, លោកជំទាវ, លោក, លោកស្រី !***

ថ្ងៃនេះខ្ញុំមានក្តីសេចក្តីសោមនស្សរីករាយ ដោយបានមកចូលរួមក្នុង **វេទិកាសេដ្ឋកិច្ចពិភពលោកស្តីពីអាស៊ានលើកទី ២៧** ដែលថ្ងៃនេះយើងលើកយកប្រធានបទដ៏សំខាន់មួយ គឺ **សហគ្រិនភាព និង បដិវត្តន៍ឧស្សាហកម្មលើកទី ៤** សម្រាប់អាស៊ានទាំងមូល ។ យើងដឹងហើយថា ចរន្តនៃការរីកចម្រើនវិទ្យាសាស្រ្ត និងបច្ចេកវិទ្យាដែលហៅថាបដិវត្តន៍ឧស្សាហកម្មទី ៤ បានក្លាយទៅជាកត្តាគន្លឹះមួយកំណត់នូវនិន្នាការវិវត្តនៃសង្គម-សេដ្ឋកិច្ចក្នុងគ្រប់ទិដ្ឋភាព ជាមួយនឹងការបង្កើតឡើងទាំងកាលានុវត្តភាព ទាំងបញ្ហាប្រឈមសម្រាប់សកលលោកទាំងមូល ។

ជាការពិត បដិវត្តន៍ឧស្សាហកម្មទី ៤ កំពុងបង្ហាញពីការរីកចម្រើននៃបច្ចេកវិទ្យានៅក្នុងពិភពលោក ដែលជះឥទ្ធិពលយ៉ាងខ្លាំងលើការកំណត់ឡើងវិញនូវកត្តាផលិតកម្ម ទំនាក់ទំនងផលិតកម្ម ឥរិយាបថការប្រើប្រាស់ និងរចនាសម្ព័ន្ធសេដ្ឋកិច្ច ដូចជា ការប្រើប្រាស់បច្ចេកវិទ្យាបញ្ញាសិប្បនិមិត្ត (AI), ការប្រើប្រាស់មនុស្សយន្ត (Robot), ការបោះពុម្ភ 3D, ការប្រើប្រាស់បច្ចេកទេសជីវវិទ្យា (Biotech) ។ល។ ដែលបច្ចេកវិទ្យាទាំងនេះ បានធ្វើឱ្យមានការផ្លាស់ប្តូយ៉ាងលឿននូវក្នុងល្បឿនមួយដែលមិនធ្លាប់មានពីមុនមកក្នុងវិស័យផលិតកម្ម, អប់រំ, សុខាភិបាល, ទីផ្សារការងារ, ពាណិជ្ជកម្ម, ធុរកិច្ច, រដ្ឋបាលសាធារណៈ និងបច្ចេកវិទ្យា ។ល។ នាពេលបច្ចុប្បន្ននេះឌីជីថលូបនីយកម្មបានក្លាយទៅជាកាតាលីករកំណើនថ្មីមួយ តាមរយៈការបង្កើនផលិតភាព និង ប្រសិទ្ធភាពការងារ និងអនុញ្ញាតឱ្យសហគ្រាសធុនតូច និង មធ្យម មានលទ្ធភាពផ្សារភ្ជាប់ទៅនឹងច្រវ៉ាក់ផលិតកម្មតំបន់ និងពិភពលោក និងស្វែងរកនវានុវត្តន៍ភាពនៅក្នុងទំនិញ ឬ សេវាកម្មថ្មីៗ និងអនុញ្ញាតឱ្យប្រទេសដែលអភិវឌ្ឍន៍តិចតួច ឬ មានសេដ្ឋកិច្ចកំពុងអភិវឌ្ឍន៍អាចចាប់យកបច្ចេកវិទ្យាថ្មីៗ ដើម្បីមានឱកាសអាចហក់ឡើង (Leapfrog) រំលងឧស្សាហកម្មបែបប្រពៃណី ចូលក្នុងឧស្សាហកម្មបែបទំនើប ។

- ***ឯកឧត្តម លោកជំទាវ លោក លោកស្រី !***

ជាមួយនឹងក្តីរំពឹងថាបដិវត្តន៍ឧស្សាហកម្ម ៤.០ នឹងនាំមកនូវការអភិវឌ្ឍជាវិជ្ជមានសម្រាប់ប្រជាជាតិទាំងមូល បដិវត្តន៍នេះក៏នាំមកនូវភាពកង្វល់ច្រើន និងបញ្ហាប្រឈមមួយចំនួន ដូចជាការបាត់បង់ការងារ, ការទាមទារឱ្យមនុស្សមានកម្រិតអប់រំ និងជំនាញខ្ពស់, ការទទួលបាននូវផលប្រយោជន៍កាន់តែមិនស្មើគ្នា ដោយសារភាពមិនស្មើគ្នានៃឱកាសទទួលបាននូវចំណេះដឹង និងបច្ចេកវិទ្យា, ឧក្រិដ្ឋកម្ម ឬបទល្មើសពាក់ព័ន្ធនឹងបច្ចេកវិទ្យាព័ត៌មានដែលអាចប៉ះពាល់ដល់សន្តិសុខជាតិ និងសន្តិសុខតំបន់ទាំងមូល, កង្វះខាតនូវក្របខ័ណ្ឌគតិយុត្តិ និងបទប្បញ្ញត្តិសម្រាប់ការគ្រប់គ្រងលើសុវត្ថិភាពទិន្នន័យ (Data Security) និងសិទ្ធឯកជននៃទិន្នន័យ (Data Privacy), និងសន្តិសុខតាមប្រព័ន្ធអ៊ីនធើណេត (Cyber Security) ។ល។

ក្នុងស្មារតីនេះ ដើម្បីចាប់យកនូវការអភិវឌ្ឍជាវិជ្ជមាន និង កាត់បន្ថយកង្វល់ ខ្ញុំយល់ថាអាស៊ានគួរតែអនុវត្តនូវវិធានការណ៍មួយចំនួនដូចខាងក្រោមៈ

- **បង្កើតនូវចក្ខុវិស័យអាស៊ានរួមមួយអំពីឧស្សាហកម្ម ៤.០** (ASEAN Vision for Industry 4.0) ដែលមានលក្ខណៈគ្រប់ជ្រុងជ្រោយ និង បរិយាប័ន្ន ដោយផ្អែកលើគំនិតផ្តួចផ្តើមរបស់អាស៊ាន ដែលមានស្រាប់ ព្រមទាំងរួមបញ្ចូលកម្មវិធីអភិវឌ្ឍន៍សំខាន់ៗលើផ្នែកបច្ចេកវិទ្យា ការអភិវឌ្ឍធនធានមនុស្ស ក្របខណ្ឌគតិយុត្តិ ហេដ្ឋារចនាសម្ព័ន្ធផ្នែកទន់ និងរឹងរបស់បច្ចេកវិទ្យាព័ត៌មាន និង កម្មវិធីកែទម្រង់របស់អាស៊ាន និង ប្រទេសជាសមាជិកនីមួយៗផងដែរ ។
- **រៀបចំកម្មវិធីរួមពង្រឹងសមត្ថភាពមនុស្ស** តាមរយៈការលើកកម្ពស់គុណភាពនៃការអប់រំ, ការបណ្តុះ-បណ្តាលជំនាញការដោះស្រាយបញ្ហាបាត់បង់ការងារ ការរៀបចំប្រព័ន្ធគាំពារសង្គម ដើម្បីដោះស្រាយបញ្ហាវិសមភាពសេដ្ឋកិច្ច និង សង្គម ។
- **លើកកម្ពស់ការរៀបចំជាប្រព័ន្ធអេកូឡូហ្ស៊ី** ដែលគាំទ្រការស្រាវជ្រាវ និងនវានុវត្តន៍ក្នុងតំបន់ ពង្រឹងនូវសមត្ថភាពសហគ្រិនភាពក្នុងការរៀបចំម៉ូឌែលធុរកិច្ច, បង្កើតការងារថ្មី និងតម្រង់ទិសថ្មីរបស់សេដ្ឋកិច្ចនាពេលអនាគត ។
- **បន្តកែលម្អហេដ្ឋារចនាសម្ព័ន្ធទាំងផ្នែករឹង និងទន់** ជាពិសេសបង្កើនការតភ្ជាប់ដែលមានស្រាប់ក៏ដូចជាការបន្តធ្វើសមាហរណកម្មទាំងក្នុងតំបន់ និងអន្តរតំបន់ ដើម្បីបន្តកសាងមូលដ្ឋានគ្រឹះរឹងមាំសម្រាប់ប្រជាជាតិអាស៊ាន ដើម្បីទាញយកផលប្រយោជន៍ពីស្ថានភាពកំណើនថ្មីក្នុងពិភពលោកនេះ។

- ***ឯកឧត្តម លោកជំទាវ លោក លោកស្រី !***

កម្ពុជាជាប្រទេសមានសក្តានុពលខ្ពស់ក្នុងការចាប់យកនូវប្រយោជន៍ ដែលកើតចេញពីបដិវត្តន៍ឧស្សាហកម្មទី ៤ នេះ ដោយមូលហេតុដូចតទៅ ÷ (១) ភាគលាភប្រជាសាស្ត្រ ដោយសារការកើនឡើងនូវចំនួនយុវជនមានចំណេះដឹង និង និន្នាការចាប់យកបច្ចេកវិទ្យាឌីជីថលលឿន, (២) ការកើនឡើងលឿននៃការប្រើប្រាស់ប្រព័ន្ធ

ទូរស័ព្ទចល័ត និង ទូរស័ព្ទវៃឆ្លាតជាមួយអត្រាប្រើប្រាស់ទូរស័ព្ទដៃខ្ពស់, (៣) លំហូរនៃការវិនិយោគក្រៅប្រទេស ដែលនាំមកនូវបច្ចេកវិទ្យា និង (៤) ឌីជីថលូបនីយកម្មបានកំពុងរីកចំរើនស្ទើរគ្រប់វិស័យសេដ្ឋកិច្ចសំខាន់ៗ ជាតួយ៉ាងដូចជា ក្នុងវិស័យបច្ចេកវិទ្យាហិរញ្ញវត្ថុ (Fintech) និង ពាណិជ្ជកម្មអេឡិកត្រូនិច (E-Commerce) ស្របពេលដែលអតិថិជនកំពុងសម្របខ្លួនជាបណ្តើរៗក្នុងការប្រើប្រាស់នូវបច្ចេកវិទ្យានានា ។

ក្នុងន័យនេះ រាជរដ្ឋាភិបាលបានកំពុងរៀបចំ និងកែសម្រួលគោលនយោបាយ ឱ្យស្របទៅតាមនិន្នាការនេះក្នុងការចាប់យកឱកាស, ជំរុញការរីកចម្រើននៃទីផ្សារធុរកិច្ចបច្ចេកវិទ្យា, គ្រប់គ្រងបរិស្ថានធុរកិច្ច ក៏ដូចជាកាត់បន្ថយនូវហានិភ័យ ដែលអាចកើតឡើងជាយថាហេតុដោយបច្ចេកវិទ្យាទាំងនេះ ។ ការរៀបចំខ្លួនសម្រាប់សេដ្ឋកិច្ចឌីជីថល និង ឆ្លើយតបទៅនឹងបដិវត្តន៍ឧស្សាហកម្មទី ៤ បានក្លាយជាទិសដៅអាទិភាពមួយរបស់រាជ-រដ្ឋាភិបាល ក្នុងអាណត្តិថ្មីនេះ ដោយត្រូវផ្តោតសំខាន់ទៅលើការពង្រឹង និង ពង្រីកមូលដ្ឋាននៃសេដ្ឋកិចឌីជីថលទាំងផ្នែករឹងនិងទន់, ការរៀបចំអភិវឌ្ឍធនធានមនុស្ស និង ជំនាញស្របតាមបរិបទថ្មី, ការបង្កើតក្របខ័ណ្ឌគតិយុត្តិ និង បទប្បញ្ញត្តិគាំទ្រដែលពាក់ព័ន្ធ ព្រមទាំងការជំរុញ និងលើកកម្ពស់ការស្រាវជ្រាវ និងនវានុវត្តន៍ ។ កម្ពុជាក៏កំពុងយកចិត្តទុកដាក់ ក្នុងការលើកកម្ពស់សហគ្រិនភាព និងការអភិវឌ្ឍសហគ្រាសធុនតូច និងមធ្យម ក្នុងការបង្កើតការងារសមរម្យថ្មី និងតម្រង់ទិសថ្មី ជាពិសេសលើ÷ **ទី១.** កម្មវិធីពង្រឹងសមត្ថភាពដែលផ្តោតលើការណ្ដុះ-បណ្តាលបំណិនសហគ្រិនភាព និងជំនាញគ្រប់គ្រងអាជីវកម្ម រួមទាំងការបណ្តុះវប្បធម៌ និង ឥរិយាបទសហគ្រិនភាពតាមរយៈវេទិកាឌីជីថល (Digital Platform) និង **ទី២.** កម្មវិធីគាំទ្រធុរកិច្ច ដែលមានផ្តោតលើការផ្តល់ការប្រឹក្សាធុរកិច្ច, ការគាំទ្រផ្នែកបច្ចេកវិទ្យាព័ត៌មាន រួមទាំងការរៀបចំមជ្ឈមណ្ឌលស្រាវជ្រាវ និង អភិវឌ្ឍន៍ ។

មុននឹងបញ្ចប់ ខ្ញុំសូមអរគុណរដ្ឋាភិបាល និង ប្រជាជនវៀតណាមចំពោះការអញ្ជើញ និង បដិសណ្ឋារកិច្ចយ៉ាងកក់ក្តៅ និង សូមជូនពរឱ្យវេទិការនេះ ប្រព្រឹត្តទៅដោយភាពជោគជ័យ ជាមួយនឹងលទ្ធផលដ៏ត្រចះត្រចង់ប្រកបដោយផ្លែផ្កាសម្រាប់បម្រើដល់ផលប្រយោជន៍រួមដល់អាស៊ានទាំងមូល ។

***សូមអរគុណ !***